ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣៤៩

ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨

**សាលដីកា**

លេខ : ១៩៥

ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០២

# នាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ ដោយមានសមាសភាព ដូចតទៅ :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | ឃឹម ប៉ុណ្ណ | ជាប្រធាន |
| ២- | លោក | រៀល មួន | ជាចៅក្រម |
| ៣- | លោក | ជីវ កេង | ជាចៅក្រម |
| ៤- | លោក | ស៊ិន ឌឹម | ជាចៅក្រម |
| ៥- | លោក | គង់ គីរុន | ជាចៅក្រម |
| ៦- | លោក | ឈឹម ស៊ីផល | ជាចៅក្រម |
| ៧- | លោក | សោម សិរីវឌ្ឍ | ជាចៅក្រម |
| ៨- | លោក | ប្រាក់ គឹមសាន | ជាចៅក្រម |
| ៩- | លោក | យស់ សូខឿន | ជាចៅក្រម |

ក្រឡាបញ្ជី

លោក ស៊ិន ភារៈ

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

លោក ប៉ែន ស៊ុនជាចៅក្រម-របាយការណ៍(អវត្តមាន)

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៥៥ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ និល អួន (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៧ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល ។

និងចុងចម្លើយឈ្មោះណៃ រ៉ាវី (ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល ។ ឪពុកឈ្មោះស៊ិន ណៃ " រ " ម្តាយឈ្មោះ មី " ស " ។

កម្មវត្ថុបណ្ដឹង : ប្ដឹងសុំបើកផ្លូវសាធារណៈ ។

បានឃើញបណ្ដឹងសាទុក្ខលើកទី២លេខ៣៦៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះ ណោ ភារី ប្ដឹងមិនសុខចិត្តពីសាលដីកាលេខ៩៥៥ ចុះថ្ងៃទី២០-៨-១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្ដីសំរេចទាំងមូល។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៤៩ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១១-១២-៩៤ របស់ឈ្មោះនិល អូន" ដើមចោទ" ប្ដឹងទាមទារឱ្យឈ្មោះសេង ធី បើកផ្លូវសាធារណៈ ចេញ-ចូល មុខផ្ទះរបស់ខ្លួន ដើម្បីឱ្យខ្លួនបានប្រើប្រាស់តទៅ ព្រោះផ្លូវនេះមានតាំងពីដូនតាមក ហើយឈ្មោះសេង ធី និង ប្រពន្ធ ឈ្មោះ ណោ ភារី បានធ្វើរបងបិទផ្លូវនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៤៥"គ" ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៥ របស់របស់តុលាការខេត្តកណ្ដាល ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១១-០២-៩៤ របស់ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២- បង្គាប់ឱ្យនាង និល អូន" ដើមចោទ" បង់ប្រាក់ប្រដាប់ក្ដីសរុប៧,០០០រៀល ក្នុងនោះពន្ធហ្វ្លឹងនិងចុះបញ្ជីក្ដី១,៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល និងពន្ធលើការស៊ើបអង្កេត៥,០០០រៀល ប្រាក់នេះដើមចោទ បានបង់រួចហើយ ។

៣- សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវឧទ្ធរណ៍រយៈពេលពីរខែ ។

បានឃើញបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះនិល អូន ចុះថ្ងៃទី១៤-៧-៩៥ ប្ដឹងមិនសុខចិត្តលើសេចក្ដីសំរេច នៃសាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ១៣៤ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៦ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១- ទទួលបណ្ដឹងឧទ្ធរណ៍របស់នាង និល អូន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់ នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៤៥" គ" ចុះថ្ងៃទី១៤-៧-៩៥របស់តុលាការ ខេត្តកណ្ដាល ទុកជាបានការពេញទាំងមូល ។

៣- បង្គាប់ឱ្យនាងនិល អួន បង់ពន្ធសមាមាត្រ មួយភាគរយលើតម្លៃដី ដែលជាផ្លូវដើរជាក់ស្តែង ។ ប្រាក់ពន្ធនេះ៨០ភាគរយ ដាក់ចូលថវិកាជាតិ និង២០ភាគរយ ដាក់ចូលក្នុងហិបក្រឡាបញ្ជីទូទាំងប្រទេស ។

៤- រឹបអូសប្រាក់ប្រដាប់ក្តី នៅជាន់សាលាឧទ្ធរណ៍ ដែលនាង និល អួន បានបង់គឺពន្ធហ្លឹង និងពន្ធចុះបញ្ជីក្តី៧,៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ៥,០០០រៀលនិងចំណាយលើអាជ្ញាធរតុលាការ៥,០០០រៀល សរុប១៣,០០០រៀល។

៥- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី សំរេចបើកផ្លូវសាទុក្ខ រយៈពេលពីរខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងសាទុក្ខ៨៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៦ របស់ឈ្មោះនិល អួន ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១១៥ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៩៧របស់តុលាការកំពូល ដែលមានខ្លឹមសារ សំរេចដូចតទៅ :

១- ទទួលបណ្តឹងសាទុក្ខលេខ៨៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៦របស់អ្នកស្រីនិល អួន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ១៣៤ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៥៣ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៦ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩,០០០រៀល ដែលអ្នកស្រីនិល អួន បានបង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន៤,០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន១៥,០០០រៀល សរុប១៩,០០០រៀល ហើយតំរូវឱ្យអ្នកស្រីណេ រ៉ាវី សងប្រាក់ចំនួន១៩,០០០រៀល នេះទៅអ្នកស្រីនិល អួន វិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៧ ។

បានឃើញសាលដីការបៀបលេខ២៣ ចុះថ្ងៃទី១២-៥-៩៨របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារសំរេចដូចតទៅ :

- ចាត់ចៅក្រមប្រឹក្សាចុះពិនិត្យផ្លូវទំនាស់ដែលមានសភាពមិនច្បាស់លាស់ដល់ទីកន្លែង ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥៥៥ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសំរេចដូចតទៅ :

១- ទទួលជំនុំជំរះរឿងក្តីនេះសារឡើងវិញ តាមអំណាចសាលដីកាលេខ១១៥ ចុះថ្ងៃទី៨-៧-៩៧របស់តុលាការកំពូល ។

២- បដិសេធសាលក្រមលេខ៨៥" គ" ចុះថ្ងៃទី១៤-៧-៩៥របស់ តុលាការខេត្តកណ្តាលចោលជាអសារបង់ ។

៣-បង្គាប់ឱ្យឈ្មោះ សេង ធី ប្រពន្ធឈ្មោះណេ ភារី បើកផ្លូវទំនាស់តាមលំនាំដើមឡើងវិញ ដោយវាយរបងថ្មដែលខ្លួនបានសង់ប៉ះពាល់លើផ្លូវនេះ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣,០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធភ្លើង២,៥៥០រៀលរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀលចំណាយលើដីកាកោះ៥,០០០រៀល និងអាជ្ញាធរតុលាការ៥,០០០រៀល ។

៥- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៣៦៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៨របស់អ្នកស្រី ណេ ភារី បានប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៥៥៥ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាការពាររបស់ឈ្មោះណេ ភារី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍ .

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា :

បណ្តឹងសាទុក្ខរបស់ចុងចម្លើយស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

សាលដីការដ្ឋប្បវេណីលេខ៥៥៥ ចុះថ្ងៃទី២០-៨-១៩៩៨ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សា ជំនុំជំរះសំរេចតាមច្បាប់ ។

ក្រឡាបញ្ជីអានសារណារបស់អ្នកស្រីណោ រ៉ាវី ជាម្ចាស់បណ្តឹងសាទុក្ខ ។

បានស្តាប់ចម្លើយរបស់អ្នកស្រីនិល អូន ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះ : បានឆ្លើយថា: ខ្លួនប្តឹងទាមទារឱ្យឈ្មោះសេង ធី បើកផ្លូវសាធារណៈចេញ-ចូល មុខផ្ទះរបស់ខ្លួន ដើម្បីឱ្យខ្លួនបានប្រើប្រាស់តទៅ ព្រោះផ្លូវនេះមានតាំងពីដូនតាមក ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ ,

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ,

-ក្រោយពីបានស្តាប់សារណារបស់ចុងចម្លើយនិងចម្លើយដោះសាររបស់ដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថាបណ្តឹងសាទុក្ខលេខ៣៦៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៨ របស់អ្នកស្រីណោ រ៉ាវី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា២២៦នៃ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានប្រសិទ្ធិភាពអនុវត្តលើរឿងរដ្ឋប្បវេណីផងដែរ ។

យល់ឃើញថាការលើកឡើងរបស់អ្នកស្រីណោ រ៉ាវី ក្នុងសារណាចុះថ្ងៃទី២៨-០១-៩៩ ថា: នៅពេលដែលអ្នកស្រីបិទផ្លូវក្នុងដីឡូតិ៍កម្មសិទ្ធិរបស់អ្នកស្រី ពុំមានអ្វីប៉ះពាល់ដល់អ្នកស្រីនិល អូន ទេ ពីព្រោះ អ្នកស្រីនិល អូន មានផ្លូវសាធារណៈ នៅក្រោយផ្ទះស្រួលហើយនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះផ្លូវទំនាស់នេះជាផ្លូវដែលមានតាំងពីមុនឆ្នាំ១៩៧៩ ហើយអ្នកស្រីនិល អូន បានប្រើប្រាស់ផ្លូវនេះតាំងពីក្រោយឆ្នាំ១៩៧៩រហូតមកដល់ពេលមានទំនាស់ដែលការបិទនេះ ពិតជាធ្វើឱ្យមានការលំបាកដល់អ្នកស្រីនិល អូន និង ប្រជាជនជាច្រើនទៀត ប្រាកដមែន ។

យល់ឃើញថាតាមគំនូសប្លង់ទីតាំងដីទំនាស់ចុះថ្ងៃទី១៣-៩-៩៦របស់ភូមិបាលស្រុកមុខកំពូល ទទឹងដីផ្លូវទំហំ៣,៥០ម ហើសាលាឧទ្ធរណ៍ក៏ពុំទាន់បានបញ្ជាក់ឱ្យច្បាស់អំពីទំហំផ្លូវនោះទេ ។ ម្យ៉ាងទៀតក្នុងការយល់ឃើញ សាលាឧទ្ធរណ៍យល់ឃើញថាចុងចម្លើយបានធ្វើ របងបិទផ្លូវអស់ប្រហែល ១មx១០ម ។ ការយល់ឃើញនេះខុសពីគំនូសប្លង់សូរិយោដី ស្រុកមុខកំពូលដែលគូរបញ្ជាក់ថាចុងចម្លើយបិទផ្លូវ ៣,៥០ម x ១៧,៥០ម ។ ដូច្នេះតុលាការកំពូល គប្បីសំរេចបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ ។

យល់ឃើញថាប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីរបស់ចុងចម្លើយលេខ J₉០០៥ D ពុំមានសុពលភាពគ្រប់គ្រាន់ទេ ពីព្រោះប័ណ្ណនេះពុំមានចុះថ្ងៃខែឆ្នាំទេ ហើយប័ណ្ណនេះបានក្លោបយកដីផ្លូវសាធារណៈទាំងមុខទាំងក្រោយ ធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយថែមទៀត ។ ដូច្នេះតុលាការកំពូលគប្បីសំរេចឱ្យកែតម្រូវប័ណ្ណនេះឱ្យបានត្រឹមត្រូវឡើងវិញ ។

យល់ឃើញថាផ្លូវទំនាស់ត្រូវបានលោកសេង ជី និងអ្នកស្រីណោ រ៉ាវី បានបិទនៅឆ្នាំ១៩៨៨ម្តង និង១៩៩៧ម្តង។ ប៉ុន្តែរដ្ឋអំណាចមូលដ្ឋានបានដោះស្រាយមិនឱ្យបិទទេ ។ លុះមកដល់ឆ្នាំ១៩៩៤ចុងចម្លើយបានបិទម្តងទៀតដែល ធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ដើមចោទ ដែលគប្បីតុលាការកំពូលលើកយកមកពិចារណា ។

យល់ឃើញថាចុងចម្លើយបានធ្វើសារណាជូនមកតុលាការកំពូលហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៥៥៥ ចុះថ្ងៃទី២៣-១១-៩៨របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ
## ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ៣៦៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៨របស់អ្នកស្រីណោ រ៉ាវី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ខ្លះ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៥៥៥ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

៣- សំរេចបន្ថែមថា:

(ក) ទំហំផ្លូវទំនាស់គឺទទឹង៣,៥០ម ។

(ខ) បង្គាប់ឱ្យការិយាល័យសុរិយោដី ស្រុកមុខកំពូល កែសំរួលប័ណ្ណសំគាល់សិទ្ធិរបស់ចុងចម្លើយ ដោយបញ្ជាក់ថ្ងៃខែឆ្នាំ និងដកទំហំដីផ្លូវសាធារណៈចេញ ។

៤- រីបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទ បានបង់ជួសនៅតុលាការកំពូលចំនួន ១៩,០០០រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន៤,០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥,០០០រៀល សរុប១៩,០០០រៀល ហើយតំរូវឱ្យចុងចម្លើយសងប្រាក់ចំនួន១៩,០០០រៀល នេះទៅដើមចោទវិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ ។